# ទំនុកដំកើង ១២៨

រ៉ូហ្វ លេភិឡារ

ពាក្យគន្លឹះនៅក្នុងទំនុកដំកើងនេះគឺ *ពរ* (*Bless*) (ខ. ១, ២, ៤, ៥)។ ពាក្យហេព្រើរអាចត្រូវបានបកប្រែជា «ពរ» ឬជា «សុភមង្គល» (គខប)។ ទំនុកដំកើងនេះប្រើពាក្យពីរក្រុមខុសគ្នាសំរាប់ពរ ដែលក្រុមមួយនៅក្នុងបីខដំបូងដែលអាចបកប្រែជា «សប្បាយ» ហើយក្រុមមួយទៀតនៅក្នុងបីខបន្ទាប់ដែលអាចបកប្រែជា «បានពរ»។ *ពរ* នៅក្នុងខ.១ រួមបញ្ចូលផ្ទៃរឿងអំពី «ក្រោមព្រះពររបស់ព្រះ» ហើយនិង «ការស្វែងរកការបំពេញសំរេចឬសុភមង្គលផ្ទាល់ខ្លួន»។ ទំនុកដំកើងនេះថ្លែងថា អ្នកដែលកោតខ្លាចដល់ព្រះអម្ចាស់នឹងបានពរនៅក្នុងជីវិតផ្ទាល់ខ្លួនរបស់គេនៅពេលបច្ចុប្បន្ន (ខ. ២-៤) ហើយក្នុងជីវិតសាធារណៈនិងក្នុងពេលអនាគត (ខ. ៥-៦)។ នៅក្នុងទំនុកដំកើងនេះ ព្រះពរបានមកដល់បុគ្គលម្នាក់ដែលកោតខ្លាចព្រះទៅក្រុមគ្រួសាររបស់គាត់ និងជាចុងក្រោយទៅអ៊ីស្រាអែល។ ដូច្នេះ ទំនុកដំកើងនេះពណ៌នាអំពីសេចក្ដីសុចរិតហើយនិងសន្តិភាពនិងស្ថិរភាពរបស់វា។ ដូចជាទំនុកដំកើង ១២៧ ដែរ ទំនុកដំកើងនេះគឺជាទំនុកដំកើងសំរាប់ក្រុមគ្រួសារទាំងឡាយ។ ទំនុកដំកើង ១២៧ បង្រៀនយើងថា ព្រះពរមកលើក្រុមគ្រួសាររបស់យើងអាស្រ័យលើព្រះពរដែលមកពីព្រះ។ ទំនុកដំកើង ១២៨ បង្រៀនយើងថា ផ្លូវតែមួយក្នុងការទទួលបានព្រះពរនោះគឺត្រូវតែរស់នៅដោយកោតខ្លាចដល់ព្រះហើយនិងចុះចូលចំពោះទ្រង់។ ដូចទំនុកដំកើង ១២៧ ដែរ ទំនុកដំកើងនេះស្រដៀងនឹងអក្សរសាស្ត្រខាងប្រាជ្ញាដោយព្រោះវាមានផ្ទៃរឿងស្រដៀងគ្នាអំពីការកោតខ្លាចព្រះអម្ចាស់ហើយនិងជីវិតប្រចាំថ្ងៃរបស់បុគ្គល ក្រុមគ្រួសារ និងសង្គម។

ដូចទំនុកដំកើង ១២៦ និង១២៧ ដែរ ទំនុកដំកើងនេះបែងចែកជាពីរផ្នែកយ៉ាងមានសណ្ដាប់ធ្នាប់ (១-៣ និង៤-៦) ដែលមានរចនាសម្ព័ន្ធស្រដៀងគ្នា។ ខ.១ មានពរហើយអស់អ្នកដែលកោតខ្លាចដល់ព្រះយេហូវ៉ា ខ.៤ មើល មនុស្សដែលកោតខ្លាចព្រះយេហូវ៉ានឹងបានពរយ៉ាងនោះហើយ។ ខ.២ ភាពចម្រុងចម្រើនរបស់បុគ្គល ខ.៥ ភាពចម្រុងចម្រើនរបស់យេរូសាឡឹម។ ខ.៣ កូនៗ ខ.៦ ចៅៗ។

**ខ. ១** អស់អ្នកដែលមានឥរិយាបថត្រឹមត្រូវនៅក្នុងចិត្ត គឺពួកគេកោតខ្លាចដល់ព្រះអម្ចាស់ បង្ហាញការនេះនៅក្នុងជីវិតរបស់ពួកគេដោយការដើរនៅក្នុងផ្លូវរបស់ព្រះដែលព្រះបន្ទូលរបស់ទ្រង់បានបើកសំដែង។ សុភមង្គលពិតប្រាកដបានមកពីការកោតខ្លាចដល់ព្រះអម្ចាស់និងការដើរនៅក្នុងផ្លូវរបស់ទ្រង់។ មនុស្សជារឿយៗគិតថា ផ្លូវរបស់លោកិយនិងសាច់ឈាមនាំទៅដល់សុភមង្គលជាង ហើយការដើរនៅក្នុងផ្លូវរបស់ព្រះធ្វើឲ្យជីវិតមានភាពលំបាកនិងភាពធុញទ្រាន់។ ទស្សនៈនេះផ្ទុយនឹងសេចក្ដីពិត។ ទំនុកដំកើង ១៤ បង្ហាញអំពីលទ្ធផលនៃការដើរតាមផ្លូវរបស់យើងផ្ទាល់ (ប្រៀបធៀប អេសាយ ៥៣:៦)។ ការដើរនៅក្នុងផ្លូវរបស់ពួកមនុស្សមានបាបនាំទៅរកសេចក្ដីវិនាស តែការដើរនៅក្នុងផ្លូវរបស់ព្រះនាំទៅរកសុភមង្គលវិញ។

**ខ. ២** *បរិភោគផល* មិនគ្រាន់តែជារូបភាពមួយនៃភាពចម្រុងចម្រើននោះទេ តែក៏ជារូបភាពនៃសន្តិភាពផងដែរ (យេរេមា ៣១:៥)។ ម្ដងទៀត យើងឃើញថាយើងត្រូវតែធ្វើការងារ ប៉ុន្តែនៅពេលព្រះប្រទានពរ នោះយើងរីករាយជាមួយនឹងផលនៃការងាររបស់យើង។

**ខ. ៣** *ដើមទំពាំងបាយជូរ* ខនេះគឺជារូបភាពមួយនៃភាពទាក់ទាញនិងការសប្បាយខាងផ្លូវភាពនៅក្នុងអាពាហ៍ពិពាហ៍ ពីព្រោះដើមទំពាំងបាយជូរគឺមិនគ្រាន់តែជានិមិត្តសញ្ញានៃភាពមានផលផ្លែនោះទេ តែក៏ជានិមិត្តសញ្ញានៃភាពទាក់ទាញខាងផ្លូវភេទ (បទចំរៀងសាឡូម៉ូន ៧:៨...) និងនៃអំណរផងដែរ (ចៅហ្វាយ ៩:១៣)។ ពាក្យ *នៅក្នុង* ដែលមិនសំដៅលើដើមទំពាំងបាយជូរ តែសំដៅលើប្រពន្ធផ្ទុយនឹងអ្វីដែលត្រូវបាននិយាយអំពីប្រពន្ធមិនរើសមុខនៅក្នុងសុភាសិត ៧:១១ ដែលរឹងមានះ ហើយនាងមិនស្នាក់នៅផ្ទះទេ។ នៅក្នុងទំនុកដំកើងនេះ ភាពទាក់ទាញរបស់ប្រពន្ធនេះបានមកពីសេចក្ដីស្មោះត្រង់របស់នាង។

*កូន...នៅជុំវិញតុ*របស់ឯង គឺជាពន្លកដើមអូលីវដែលផ្តល់សេចក្ដីសង្ឃឹមសំរាប់អនាគត។

**ខ. ៥, ៦** *ស៊ីយ៉ូន* ដែលជាកន្លែងមនុស្សស្មោះត្រង់ជួបជុំគ្នា គឺជាកន្លែងដែលអ្នកអាចរកបានព្រះពរ ហើយពួកគេគួរតែស្វែងរកភាពចម្រុងចម្រើនសំរាប់យេរូសាឡឹមផងដែរ។ រូបភាពនៃជីវិតយូរអង្វែងគឺជារូបភាពមួយនៅក្នុងព្រះគម្ពីរសញ្ញាចាស់ក្នុងការពិពណ៌នាអំពីជីវិតដែលព្រះប្រទានពរ (លោកុប្បត្តិ ៥០:២៣, សុភាសិត ១៧:៦)។

**ការអនុវត្ត**

ទំនុកដំកើងនេះបញ្ជាក់អំពីសេចក្តីពិតផ្សេងៗដែលនៅតែពិតសំរាប់ពួកគ្រីស្ទបរិស័ទសម័យនេះ។ ព្រះយេស៊ូវបានបង្រៀនយើងឲ្យកោតខ្លាចដល់ព្រះ ហើយហៅឲ្យមនុស្សបានប្រែចិត្តនិងជឿលើដំណឹងល្អ។ យើងត្រូវតែប្រាប់ឲ្យលោកិយបានចុះចូលចំពោះទ្រង់ ស្តាប់តាមគ្រប់យ៉ាងដែលទ្រង់បានបញ្ជា (ម៉ាថាយ ២៨:១៦-២០)។ ក្នុងការធ្វើដូច្នោះ មនុស្សនឹងបានព្រះពរពីព្រះ ពីព្រោះទ្រង់បានមានបន្ទូលដដែលៗថា អស់អ្នកណាដែលស្តាប់តាមសេចក្តីបង្រៀនរបស់ទ្រង់នឹងទទួលបានព្រះពរ (ឧទាហរណ៍ ម៉ាថាយ ៥:១-១២)។ កុំឲ្យចុះចាញ់សេចក្តីល្បួងនិងសេចក្តីកំភូតរបស់លោកិយដែលទាក់ទាញទឹកចិត្តដោយការសន្យាអំពីជីវិតសប្បាយរីករាយតាមរយៈការបះបោរប្រឆាំងនឹងព្រះ ហើយការដើរនៅក្នុងផ្លូវរបស់ខ្លួនឯងយើងឲ្យសោះ។ ឳពុកម្តាយដែលជាគ្រីស្ទបរិស័ទគួរតែចងចាំផងដែរថា សុភមង្គលសំរាប់ក្រុមគ្រួសារទាំងមូលមិនមែនបានមកតាមរយៈទ្រព្យសម្បត្តិសម្ភារៈនោះទេ ប៉ុន្តែវាបានមកតាមរយៈការកោតខ្លាចដល់ព្រះនិងការដើរតាមផ្លូវរបស់ទ្រង់វិញ។

**Bibliography**

Carson, D.A., R. T. France, J. A. Motyer & G. J. Wenham, Ed. (1994), *New Bible commentary: 21st century edition*, (4th ed.) Leicester, England; Downers Grove, IL: Inter-Varsity Press.

Henry, M. (1994), *Matthew Henry's commentary on the whole Bible: Complete and unabridged in one volume*, Peabody: Hendrickson.

Keil, C. F., & Delitzsch, F. (1996). *Vol. 5*: *Commentary on the Old Testament*. Peabody, MA: Hendrickson.

Kidner, D. (1975). *Vol. 16*: *Psalms 73–150: An Introduction and Commentary*. Tyndale Old Testament Commentaries. Nottingham, England: Inter-Varsity Press.

Wilcock, Michael. (2001), *The Message of Psalms 73-150.* The Bible Speaks Today Commentaries. Leicester, England: Inter-Varsity Press.